**បទអន្តរាគមន៍របស់**

**ឯកឧត្តម ឆាន់ សារ៉ាដាន រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**និងជាប្រធានក្រុមការងារបច្ចេកទេសចំរុះសំរាប់កំណែទំរង់ដីធ្លី**

**( GDCC, ថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ២០០៨ )**

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !**

រាជរដ្ឋាភិបាលបានយល់ស្របជាមួយដៃគូអភិវឌ្ឍន៍ថា វិស័យដីធ្លីគឺជាវិស័យមួយក្នុងចំណោមវិស័យធនធានធម្មជាតិជាច្រើនរបស់កម្ពុជា ហើយការគ្រប់គ្រងធនធានធម្មជាតិត្រូវតែគ្រប់គ្រងប្រកបដោយនិរន្តរភាព សមធមិ និងមានតម្លាភាព ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងកាត់បន្ថយភាពក្រីក្រសំរាប់ប្រជាពលរដ្ឋកម្ពុជា។ ដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់ដៃគូអភិវឌ្ឍន៍ សូមអនុញ្ញាតឱ្យខ្ញុំធ្វើការបកស្រាយដោយសង្ខេបនូវអ្វី ដែលរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងអនុវត្តកន្លងមកដូចខាងក្រោម ÷

**<u>ការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ :</u>**

តាមនាមឱ្យរដ្ឋាភិបាលខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេកដែលដៃគូអភិវឌ្ឍន៍បានទទួលស្គាល់នូវសមិទ្ធផល ដ៏ធំធេងលើចំនុចនេះ។ គិតត្រឹមចុងឆ្នាំ ២០០៧ លទ្ធផលសរុបនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធចាប់តាំងពីថ្ងៃអនុវត្តរាជរដ្ឋាភិបាលបានវាស់វែង និងធ្វើការវិនិច្ឆ័យក្បាលដីចំនួន ១.០៦១.៤១៤ ក្បាលដី ហើយបានចែកកម្មសិទ្ធដីធ្លីដល់ដៃប្រជាពលរដ្ឋចំនួន ៧៩៤.៦៣៩ ក្បាល នៅក្នុងខេត្តចំនួន ១១។

**<u>សម្បទានដីសង្គមកិច្ច</u>**

គំរោងសាកល្បង LASED បានចុះបញ្ជីដីឯកជនរបស់រដ្ឋទំហំ សរុប ៤.៧៧០,២២ ហិចតា។ នៅក្នុងឃុំសំបុក ៣២៩៤,៣៦ ហិចតា ឃុំចង្រ្កង ៦១២,២១ហិចតា នៅស្រុកក្រចេះ នៅខេត្តក្រចេះ។ ចំណែកទីតាំងមួយទៀតគឺនៅឃុំជាំក្រវៀន ក្នុងស្រុកមេមត់ ខេត្តកំពង់ចាម ទំហំ ៨៦៣,៦៥ ហិចតា។ ដីឯកជនរបស់រដ្ឋទាំងនេះនឹងត្រូវចែកជូនប្រជាពលរដ្ឋក្រីក្រគ្មានដី និងគ្រួសារក្រីក្រក្រោមកម្មវិធីដីសម្បទានសង្គមកិច្ច។

យោងតាម Aide Memoire រវាងរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោកនៅខែធ្នូ ២០០៧ ធនាគារពិភពលោកនឹងគាំទ្រគំរោង LASED សំរាប់រយៈពេល៥ឆ្នាំ ចាប់ពីខែកក្កដា ឆ្នាំ២០០៨ ដល់មិថុនា ឆ្នាំ២០១៣។ គំរោងនេះនឹងត្រូវអនុវត្តនៅក្នុងខេត្តបីគឺ ខេត្តកំពង់ចាម ក្រចេះ និង កំពង់ធំ។ ក្នុងខេត្តទាំងបីនេះ មាន២០ឃុំ នៅក្នុងស្រុកចំនួន៩ ក្នុងនោះមាន ១៧ ឃុំថែមលើឃុំចំនួន ៣ ដែលកំពុងអនុវត្តជាលក្ខណៈសាកល្បងនឹងត្រូវបានគាំទ្រដោយគំរោងសំរាប់ការរៀបចំ និងអនុវត្តសម្បទានដីសង្គមកិច្ច។

រដ្ឋាភិបាលបានបញ្ជាក់ឃុំចំនួន៧ នៅខែមករាឆ្នាំ២០០៨ សំរាប់ធ្វើការចុះបញ្ជីជាដីឯកជនរបស់រដ្ឋដើម្បីអនុវត្តសម្បទានដីសង្គមកិច្ចឆ្នាំ ២០០៨ ហើយ ចំនួនឃុំដែលនៅសល់របស់គំរោងនឹងបញ្ជាក់បន្ថែមនៅ ពាក់កណ្តាលឆ្នាំ ២០០៨ ខាងមុខ។

លើសពីនេះ គំរោងបានគាំទ្រអាជ្ញាធរមូលដ្ឋានដើម្បីរៀបចំទំហំដីប្រមាណ ១៣.៥ ហិចតា សំរាប់គោលបំណងដីសម្បទានសង្គមកិច្ចនៅសង្កាត់ក្បាលឆាយ ក្រុងព្រះសីហនុ។ ដីសម្បទាននេះគ្រោងនឹងចែកជូនប្រជាពលរដ្ឋក្រីក្រចំនួន ២៥៩ គ្រួសារ។ នៅខេត្ត កំពត រដ្ឋាភិបាលបានដកហូតដីទំហំដីប្រមាណ ២១៩ ហិចតាពីការទន្ទ្រានកាន់កាប់ខុសច្បាប់ ហើយដីនេះមួយផ្នែកគ្រោងសំរាប់ដីសម្បទានសង្គមកិច្ចដើម្បីចែកជូនដល់ប្រជាពលរដ្ឋក្រីក្រចំនួន១២២ គ្រួសារ ហើយដីដែលនៅសល់នឹងគ្រោងសំរាប់ដាំព្រៃឈើឡើងវិញ។

## គោលនយោបាយស្តីពីការចុះបញ្ជីដីធ្លី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច

សេចក្តីព្រាងគោលនយោបាយនេះត្រូវបានបញ្ជូនទៅដល់ទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ៧ ខែឧសភា ឆ្នាំ ២០០៧ ហើយត្រូវបានពិភាក្សាជាមួយ OBSES នៅ ខែ សីហា ឆ្នាំ ២០០៧។ អង្គប្រជុំបានឯកភាពលើខ្លឹមសារទាំងស្រុងលើសេចក្តីព្រាងគោលនយោបាយនេះ ដោយគ្រាន់តែស្នើសុំកែសម្រួលពាក្យពេចន៍និងឃ្លាឃ្លោងមួយចំនួនប៉ុណ្ណោះ។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការចុះបញ្ជីដីសហគមន៍របស់ជនជាតិដើមភាគតិចត្រូវបានរៀបចំឡើង។ សេចក្តីព្រាងនេះត្រូវបានពិភាក្សានៅអគ្គលេខាធិការដ្ឋានគោលនយោបាយដីធ្លីរួច (CLP) ហើយក្រសួង ដ.ន.ស.កំពុងពិនិត្យឡើងវិញ។ សេចក្តីព្រាងនេះនឹងត្រូវបញ្ជូនទៅឱ្យភាគីពាក់ព័ន្ធដើម្បីធ្វើការពិគ្រោះយោបល់តាមរយៈ Email នៅខែមិនា ២០០៨។ បន្ទាប់មក សមាជិក CLP នឹងពិនិត្យឡើងវិញ មុននឹងដាក់ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី និងសមាជិក CPL ទាំងអស់ធ្វើការអនុម័ត។ សេចក្តីព្រាងអនុក្រឹត្យនេះរួមជាមួយនឹងគោលនយោបាយខាងលើនឹងរំពឹងថា នឹងត្រូវឆ្លងអង្គប្រជុំអន្តរក្រសួងមុនដាក់ចូលប្រជុំពេញអង្គ គណៈរដ្ឋ មន្ត្រីដើម្បីធ្វើការអនុម័ត។

GS-CLP ក្រសួង ដ.ន.ស. និងសមាជិក TWGL មកពីអន្តរក្រសួងបានចុះវាលនៅខេត្ត រតនៈគីរី នៅខែ ធ្នូ ២០០៧ និង នៅខេត្តមណ្ឌលគីរី នៅខែមករា ២០០៨ ដើម្បីដកស្រង់បទពិសោធន៍ពីគំរោងសាកល្បងនៅ ក្នុងភូមិបីក្នុងខេត្តទាំងពីរនេះ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងនៃអនុក្រឹត្យ និងការកំណត់ព្រំប្រទល់ជំហានដំបូងនៃសហគមន៍ជនជាតិដើមភាគតិច។

ទាក់ទិននឹងវិធានការណ៍ការពារជាបណ្តោះអាសន្ន ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញសេចក្តីជូនដំណឹងមួយនៅថ្ងៃទី ១៤ កុម្ភៈ ២០០៨ ដើម្បីអនុញ្ញាតឱ្យការសាកល្បងចុះបញ្ជីដំណើរការទៅមុខ។ មន្ទីរខេត្ត រតនគីរី និងមណ្ឌលគីរី កំពុងរៀបចំផែនការការងារសំរាប់ការចុះបញ្ជីក្នុងសហគមន៍ទាំងបីនេះ។

## ការបណ្តេញប្រជាពលរដ្ឋចេញពីតំបន់មួយចំនួន

ជាការពិតណាស់ថា ទំនាស់ដីធ្លីងាយនឹងកើតឡើងនៅក្នុងតំបន់ទីក្រុងដែលមានការអភិវឌ្ឍន៍ខ្លាំង ប៉ុន្តែទំនាស់ទាំងនេះអាចបញ្ចៀសបាន ប្រសិនបើដីធ្លីនៅក្នុងតំបន់ទាំងនោះមានឯកសារផ្លូវច្បាប់ស្តីពីការកាន់កាប់ ការកំណត់ព្រំដី និងឯកសារផ្សេងទៀតពាក់ព័ន្ធទៅនឹងការកាន់កាប់ដីធ្លី ឬអចលនទ្រព្យទាំងនោះ។

ការអនុវត្តនៅកន្លងមក ជាពិសេសចាប់តាំងពី ខែ ឧសភា ឆ្នាំ ២០០៣ រហូតមកទល់បច្ចុប្បន្ន សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី បានប្រកាសឱ្យមានការអភិវឌ្ឍន៍នៅនឹងកន្លែងនៃសហគមន៍ប្រជាជនក្រីក្ររស់នៅក្នុងសំណង់បណ្តោះអាសន្ននៅទីក្រុងភ្នំពេញ ឱ្យបាន ១០០ សហគមន៍ក្នុង ១ ឆ្នាំ ហើយរូបសម្តេចផ្ទាល់ បានបរិច្ចាគទឹកប្រាក់

ផ្ទាល់ខ្លួនចំនួន ៥ លានរៀលក្នុង ១ ខែ ដល់មូលនិធិអភិវឌ្ឍន៍សហគមន៍ប្រជាជនក្រីក្រ UPDF តាំងពីពេល នោះរហូតមកដល់បច្ចុប្បន្ន។

តាមពិតទៅ ប្រសិនបើរាជរដ្ឋាភិបាលអនុវត្តច្បាប់ភូមិបាលទាំងស្រុង និងច្បាប់ពាក់ព័ន្ធដទៃទៀត ប្រជាជនដែលបាននិងកំពុងកាន់កាប់និងរស់នៅដោយខុសច្បាប់ទាំងអស់នៅលើដីរដ្ឋ ប្រហែលជានឹងត្រូវទទួលរងនូវការបណ្តេញចេញជាមួយនឹងសំណងតិចតួចទៅវិញទេ។ បទពិសោធន៍កន្លងមក ការតាំងទីលំនៅដោយខុសច្បាប់នៅលើដីឯកជនដែលមានលិខិតស្នាមត្រឹមត្រូវរបស់ម្ចាស់ដីស្របច្បាប់ម្ចាស់ដីប្តឹងទៅតុលាការដើម្បីចេញដីកាឱ្យប្រជាជនដែលតាំងទីលំនៅដោយខុសច្បាប់ចាកចេញពីដីរបស់ម្ចាស់ដីស្របច្បាប់។ ការសំរេចរបស់តុលាការដែលជាស្ថាប័នឯករាជ្យអាជ្ញាធរដែនដីត្រូវតែអនុវត្តតាមការសំរេចនោះ ហើយនេះជាការអនុវត្តច្បាប់សំរាប់ប្រទេស ដូចជា ការអនុវត្តច្បាប់នៅទូទាំងពិភពលោកផងដែរ។ ទោះបីជាយ៉ាងនេះក៏ដោយ រាជរដ្ឋាភិបាលកម្ពុជាបានចូលខ្លួនមកអន្តរករ និងធ្វើការចរចា ជាមួយម្ចាស់ដីស្របច្បាប់ដើម្បីរកដំណោះស្រាយសមរម្យជូនដល់ប្រជាជនដែលត្រូវអនុវត្តសាលក្រមតុលាការដោយស្នើសុំឱ្យមានការដោះដូរជាថ្នូរមានជាដីនៅទីតាំងផ្សេងសំរាប់ឱ្យប្រជាជនដែលត្រូវរើចេញសាងសង់លំនៅឋាន ។

ទោះជាយ៉ាងនេះក៏ដោយ រាជរដ្ឋាភិបាលមានសុឆន្ទៈដោះស្រាយបញ្ហានេះដូចមានខាងក្រោមៈ

**១-ដំណោះស្រាយចំពោះមុខ** គឺតាមរយៈការខិតខំអនុវត្តវិធីសាស្ត្រអភិវឌ្ឍន៍នៅនឹងកន្លែង។ ជាក់ស្តែងការងារនេះបាន និងកំពុងអនុវត្តដោយអាជ្ញាធរក្រុងភ្នំពេញ និងបាត់ដំបង។ ជាក់ស្តែងកន្លង មកអាជ្ញាធរដែនដីក្រុងភ្នំពេញសហការជាមួយអង្គការជាដៃគូអភិវឌ្ឍន៍បានខិតខំរៀបចំដោះស្រាយសំណង់ខុសច្បាប់បានប្រមាណជាង ៣០០ សហគមន៍លំនៅឋានខុសច្បាប់ ក្នុងចំណោម ៥៦៩ សហគមន៍ក្នុងទីក្រុងភ្នំពេញ។ លើសពីនេះទៀត បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ចំពោះប្រជាជនក្រីក្ររស់នៅក្នុងទីតាំងលំនៅឋានខុសច្បាប់ដោយផ្តល់ជាលំនៅឋានមានគុណភាពល្អសមរម្យក្នុងទំហំ ៤ គុណនឹង ៥ ម៉ែត្រ សាងសង់ លើផ្ទៃដី ៤ គុណនឹង ៦ ម៉ែត្រ ជាការលក់ជូនប្រជាជនក្រីក្រដោយរំលោះរយៈ ពេល ៥ ឆ្នាំ មានតំលៃត្រឹមតែ ១.០០០ ដុល្លាសហរដ្ឋ អាមេរិក ដែលគំរោងនេះក្នុងជំហានដំបូងរួមអនុវត្តជាមួយអង្គការជាដៃគូអភិវឌ្ឍន៍ដទៃទៀត មានចំនួនប្រមាណជាង ៣០០ ផ្ទះ ។

**២-ដំណោះស្រាយរយៈពេលមធ្យម** តាមរយៈការកសាងផែនការអភិវឌ្ឍន៍ និងផែនការប្រើប្រាស់ដីធ្លី ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ និងប្លង់គោលរូបវ័ន្តខេត្ត ក្រុង។ ជាក់ស្តែងរាជរដ្ឋាភិបាលបាន និងកំពុងខិតខំជួយកសាងផែនការប្រើប្រាស់ដីធ្លីថ្នាក់ ឃុំបានចំនួន ៤៥ ឃុំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ស្រុកបានចំនួន ជាង ២០ និងខេត្ត ក្រុង បានចំនួន ៣ ខេត្ត ក្រុង។ ការបង្កើតឡើងនូវយន្តការដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការមានជាអាទិ៍ គណៈកម្មាធិការសុរិយោដី និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ក៏ជាយន្តការចូលរួមចំណែកទប់ស្កាត់ និងដោះស្រាយបាតុភាពទំនាស់ដីធ្លី និងការបណ្តេញចេញដោយបង្ខំ ដែលផ្ទុយទាំងស្រុងទៅនឹងការចោទប្រកាន់ខាងលើ ។

**៣-ដំណោះស្រាយរយៈពេលវែង** តាមរយៈការបន្តរៀបចំជាគោលនយោបាយដីធ្លី និងគោលនយោបាយជាតិលំនៅឋាន និងបន្តអនុវត្តកម្មវិធីដីសម្បទានសង្គមកិច្ច ដើម្បីបង្កើនលទ្ធភាព ជាពិសេស ដល់ប្រជាជនមានប្រាក់ចំណូលទាប និងក្រីក្រឱ្យទទួលបានដី និងលំនៅឋានសមរម្យ និងស្របច្បាប់សំរាប់ការរស់នៅ។ ជាក់ស្តែង រាជរដ្ឋាភិបាលបាន

និងកំពុងអនុវត្តគំរោងសាកល្បងកែលំអលំនៅឋានខុសច្បាប់នៅខេត្តបាត់ដំបងលើដីដែលអាជ្ញាធរខេត្តបានគ្រោងធ្វើសួនច្បារសាធារណៈ ដែលជាដំណោះស្រាយសំរាប់ផ្តល់លំនៅឋានជូនប្រជាជនក្រីក្រកំពុងតាំងទីលំនៅដោយខុសច្បាប់ចំនួនប្រមាណ ៦០០ គ្រួសារ ។ ដំណោះស្រាយជាគំរូសាកល្បងនេះជាបទពិសោធន៍មួយ ដែលនឹងត្រូវប្រើប្រាស់សំរាប់ការរៀបចំគោលនយោបាយជាតិលំនៅឋាន ដែលនឹងអាចយកទៅអនុវត្តសំរាប់បណ្តាសំណង់ខុសច្បាប់ដែលមាននៅក្នុងខេត្តក្រុងទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**សូមអរគុណ!**